ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ការិយាល័យសន្តិសុខថ្នាក់កណ្តាល
លេខៈ...៥១..........ស.ស.រ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតក្រុមប្រចាំការអចិន្ត្រៃយ៍របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល

## ការិយាល័យសន្តិសុខថ្នាក់កណ្តាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញសេចក្តីសំរេចលេខ ៥៥សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣

-ផ្អែកតាមការចាំបាច់របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល

## សំរេច

**ប្រការ១** : ត្រូវបានបង្កើតក្រុមប្រចាំការអចិន្ត្រៃយ៍របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ដែលមានសមាសភាពដូចខាងក្រោម :

១-ឯ.ឧ.ឧត្តមសេនីយ៍ឯក **នេត សាវឿន** អគ្គស្នងការរងនគរបាលជាតិ ជាប្រធាន

២-ឯ.ឧ.ឧត្តមសេនីយ៍ឯក **ជា តារា** នាយរងសេនាធិការចំរុះ និងជានាយកទីចាត់ការកលយុទ្ធ ជាអនុប្រធាន

៣-ឯ. ឧ. ឧត្តមសេនីយ៍ទោ **សុខ ផល** ប្រធាននាយកដ្ឋានព័ត៌មានទូទៅ ជាសមាជិក

៤-ឯ. ឧ. ឧត្តមសេនីយ៍ទោ **ខៀវ សុគីគ** អគ្គលេខាធិការរង ក្រសួងមហាផ្ទៃ ជាសមាជិក

៥-ឯ. ឧ. ឧត្តមសេនីយ៍ទោ **ម៉ៅ ចំនួនតារា** ប្រធានលេខាធិការ ជាសមាជិក

៦-ឯ. ឧ. ឧត្តមសេនីយ៍ទោ **ខៀវ ពិសេន** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាសមាជិក

<u>**ប្រការ២**</u> : ក្រុមប្រចាំការអចិន្ត្រៃយ៍មានភារកិច្ច :

-ជួយការិយាល័យសន្តិសុខថ្នាក់កណ្តាល តាមដាន ត្រួតពិនិត្យការអនុវត្តផែនការលេខ ០១៨.ក ចុះថ្ងៃទី១៣/០១/២០០៣ ស្តីពីវិធានការការពារសុវត្ថិភាពក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-តាមដាន ប្រមូលផ្តុំព័ត៌មាន សភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់ជុំវិញការឃោសនាបោះឆ្នោត និងការបោះឆ្នោត ពីបណ្តាអង្គភាពជំនាញ និងពីគ្រប់ខេត្ត-ក្រុងរាយការណ៍ជូនការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-បញ្ជាដឹកនាំដោះស្រាយរាល់សភាពការណ៍ ពេលមានករណីចាំបាច់ ឬឧប្បត្តិហេតុផ្សេងៗទាក់ទងដល់សន្តិសុខការបោះឆ្នោត ដោយសហការជាមួយការិយាល័យ សន្តិសុខថ្នាក់ខេត្ត-ក្រុង និងសមត្ថកិច្ចពាក់ព័ន្ធ ។

<u>**ប្រការ៣**</u> : ក្រុមប្រចាំការអចិន្ត្រៃយ៍មានសិទ្ធិប្រើប្រាស់ ដឹកនាំកម្លាំង និងមធ្យោបាយក្រោមឱវាទរបស់ខ្លួន ដើម្បីជាជំនួយការក្នុងកិច្ចចាំបាច់ ដើម្បីសំរេចភារកិច្ចដូចមានចែងក្នុងប្រការ២ ។

<u>**ប្រការ៤**</u> : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៣

**ឧបនាយករដ្ឋមន្ត្រី**

**និងជាប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល**

<u>**ចំលងជូន:**</u>

*-ទីស្តីការគណៈរដ្ឋមន្ត្រី*

*-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង*

*-ក្រសួងមហាផ្ទៃ*

*-ក្រសួងការពារជាតិ*

*-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*-អគ្គមេបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ*

*-អគ្គស្នងការដ្ឋាននគរបាលជាតិ*

*-បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស*

*-គ្រប់សាលាខេត្ត-ក្រុង*

*-ដូចប្រការ១*

*-ឯកសារ-កាលប្បវត្តិ*